១០ ឆ្នាំ យើងរួមគ្នាគាំទ្រកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ

ឆ្នាំនេះគឺជាខួបលើកទី ១០ នៃកិច្ចប្រជុំថ្នាក់ដឹកនាំលើកដំបូងនៃកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ។

នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៦ កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គត្រូវបានចាប់ផ្តើមជាផ្លូវការ ប្រទេសទាំង ៦ បានសាបព្រោះគ្រាប់ពូជនៃសាមគ្គីភាពក្នុងតំបន់ ការពឹងផ្អែកលើខ្លួនឯង និងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក។

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ប្រទេសឡានឆាង-មេគង្គទាំង ៦ បានពួតដៃគ្នាដើម្បីឆ្ពោះទៅមុខ ហើយចែករំលែកសុខុមាលភាព និងទុក្ខវេទនារួមគ្នា។ ប្រទេសនានាបានផ្លាស់ប្តូរគំនិត "ជោគវាសនារួម" ក្លាយទៅជាភាពកក់ក្តៅជាក់ស្តែង ហើយបញ្ចូលសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការទៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាជននៃប្រទេសទាំង ៦។

លោក ងន ប៊ុនធី មកពីប្រទេសកម្ពុជា៖ គម្រោង "ដំណើរនៃក្តីស្រឡាញ់" បានបន្សល់ទុកនូវមរតកយ៉ាងកក់ក្តៅ

អស់រយៈពេលជាច្រើនឆ្នាំមកនេះ មន្ទីរពេទ្យបេះដូង និងសរសៃឈាម Fuwai ខេត្តយូណាន បានអនុវត្តគម្រោង "ដំណើរនៃក្តីស្រឡាញ់" នៅប្រទេសកម្ពុជា ដោយផ្តល់ជូនការពិនិត្យសុខភាព និងការពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រដោយឥតគិតថ្លៃសម្រាប់កុមារដែលមានជំងឺបេះដូងពីកំណើត។ លោក ងន ប៊ុនធី អភិបាលរងស្រុកបន្ទាយស្រី ខេត្តសៀមរាប ប្រទេសកម្ពុជាធ្លាប់ធ្វើដំណើរទៅកាន់សាលារៀនជាច្រើននៅប្រទេសកម្ពុជា ដើម្បីជួយកុមារដែលមានជំងឺបេះដូងពីកំណើតក្នុងការធ្វើដំណើរទៅកាន់ខេត្តយូណាន ដើម្បីទទួលការព្យាបាល។ តាមទស្សនៈរបស់លោក គម្រោង "ដំណើរនៃក្តីស្រឡាញ់" បម្រើជាសក្ខីភាពដ៏កក់ក្តៅ និងរំជួលចិត្តបំផុតនៃកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ។

លោក ងន ប៊ុនធី បានរៀបរាប់រឿងកូនខ្មែរឈ្មោះ ប៉ែង សេឡា ជាមួយអ្នកកាសែតថា លោក ប៉ែង សេឡា បានទៅក្រុងគុនមីងក្នុងឆ្នាំ ២០១៨ ដើម្បីព្យាបាលជំងឺ ហើយបច្ចុប្បន្នគាត់ចូលរៀនក្នុងសាកលវិទ្យាល័យ និងក្លាយជានិស្សិតសាកលវិទ្យាល័យម្នាក់។ ខ្ញុំពិតជាទទួលអារម្មណ៍យ៉ាងជ្រាលជ្រៅថា សេចក្តីស្រឡាញ់និងសេចក្តីសប្បុរសគឺគ្មានព្រំដែនទេ។ លោក ងន ប៊ុនធី បានបន្ថែមថា គម្រោង "ដំណើរនៃក្តីស្រឡាញ់" មិនគ្រាន់តែជាគំនិតផ្តួចផ្តើមជំនួយផ្នែកវេជ្ជសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៅទៀត វាគឺជាស្ពានមិត្តភាពដែលភ្ជាប់ប្រជាជនកម្ពុជា និងចិន។

លោក ឡូ ក្វងស៊ីង មកពីប្រទេសចិន៖ កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ ក្លាយជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់ប្រជាជនសាមញ្ញ

លោក ឡូ ក្វងស៊ីង ប្រធានមហាវិទ្យាល័យទំនាក់ទំនងអន្តរជាតិនៃសាកលវិទ្យាល័យយូណាន និងជានាយកមជ្ឈមណ្ឌលសិក្សាអនុតំបន់ឡានឆាង-មេគង្គ បានលើកឡើងថា ចាប់តាំងពីការចាប់ផ្តើមនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបនមេគង្គ (GMS) ក្នុងឆ្នាំ ១៩៩២ រហូតដល់ក្របខណ្ឌកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ (LMC) បច្ចុប្បន្ន កិច្ចសហការវាងប្រទេសចិន និងប្រទេសមេគង្គបានឈានហួសពីវិស័យសេដ្ឋកិច្ចតែមួយមុខជាយូរណាស់មកហើយ ហើយនិងពង្រីកក្នុងវិស័យជាច្រើន រួមទាំងនយោបាយ សន្តិសុខ និងការអភិវឌ្ឍសង្គមជាដើម។

តាមទស្សនៈរបស់លោក ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គបានវិវត្តន៍ពីកិច្ចសហប្រតិបត្តិការអន្តរដឹកនាំដោយរដ្ឋាភិបាល បានពង្រីកទៅដល់ក្រប់កម្រិតនៃសង្គម ដោយក្លាយជាផ្នែកសំខាន់មួយនៃជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋសាមញ្ញ។ និស្សិតជាង ៧ 000 នាក់ដែលមកពីប្រទេសមេគង្គកំពុងបន្តការសិក្សានៅខេត្តយូណាននៃប្រទេសចិន។ គម្រោងផ្តល់ផលប្រយោជន៍ដល់សហគមន៍ក្នុងតំបន់ "ទំហំតូច ប៉ុន្តែមានអត្ថន័យសំខាន់" មួយចំនួនដែលត្រូវបានអនុវត្តនិងចាក់ឫសនៅតំបន់ជនបទ ហើយកិច្ចសហប្រតិបត្តិការក្នុងការកាត់បន្ថយភាពក្រីក្រ និងការអប់រំវិជ្ជាជីវៈបន្តជំរុញកាន់តែស៊ីជម្រៅ។

ខេត្តយូណានឈរជាខេត្តជួរមុខរបស់ប្រទេសចិនក្នុងការចូលរួមកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ។ លោក ឡូ ក្វងស៊ីង បានសង្កត់ធ្ងន់ថា ខេត្តយូណានបានបង្ហាញតាមរយៈការអនុវត្តអំពីរបៀបប្រែក្លាយភូមិសាស្ត្រជាប់ព្រំដែនគ្នាឱ្យទៅជាភាគលាភនៃការអភិវឌ្ឍដែលធ្វើឱ្យកិច្ចសហប្រតិបត្តិការមិនត្រឹមតែមានកម្រិតខ្ពស់ប៉ុណ្ណោះទេ ថែមទាំងមានភាពកក់ក្តៅផងដែរ។

លោកស្រី Sarah Moon Seng Pan មកពីប្រទេសមីយ៉ាន់ម៉ា៖ មានមិត្តភក្តិម្នាក់បន្ថែមទៀត ប្រៀបដូចបើកផ្លូវមួយបន្ថែមទៀត

លោកស្រី Sarah Moon Seng Pan ជាមន្ត្រីការទូតម្នាក់មកពីប្រទេសមីយ៉ាន់ម៉ា បានចែករំលែកថា សម្រាប់នាង កិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គធ្លាប់គ្រាន់តែជាពាក្យមួយដែលលេចឡើងជាញឹកញាប់នៅក្នុងឯកសារការងារ និងជាប្រធានបទសំខាន់នៃការពិភាក្សានៅក្នុងកិច្ចប្រជុំ ប៉ុន្តែវាតែងតែមានអារម្មណ៍ថានៅឆ្ងាយបន្តិច។ រហូតដល់ខ្ញុំមកដល់ខេត្តយូណានដើម្បីសិក្សាភាសាចិន ទើបអ្វីៗទាំងអស់ចាប់ផ្តើមមានអារម្មណ៍ពិតប្រាកដ។

នៅក្នុងថ្នាក់រៀន លោកស្រីបានសិក្សាយ៉ាងយកចិត្តទុកដាក់អំពីការបញ្ចេញសំឡេង និងវេយ្យាករណ៍ ដោយរីកចម្រើនពីឃ្លាសាមញ្ញៗ ដូចជា "សួស្តី" និង "អរគុណ" រហូតដល់ការសន្ទនាដោយទំនុកចិត្តជាមួយមិត្តរួមថ្នាក់របស់នាងជាភាសាចិន។ ដំណើរការទាំងមូលនេះមានអារម្មណ៍ដូចជាការកសាងស្ពានទំនាក់ទំនងដោយដៃរបស់នាងផ្ទាល់។ នាងបានកត់សម្គាល់ថា តាមរយៈស្ពានភាសា ខ្ញុំពិតជាបានបោះជំហានចូលទៅក្នុងជីវិតរបស់ប្រជាជនចិន ដោយជួបប្រទះនឹងភាពកក់ក្តៅ សេចក្តីសប្បុរស និងភាពស្មោះត្រង់របស់ពួកគេ ព្រមទាំងអាចចែករំលែករឿងរ៉ាវអំពីប្រទេសមីយ៉ាន់ម៉ាជាមួយមិត្តភក្តិចិនរបស់ខ្ញុំផងដែរ។

ថ្ងៃនេះ លោកស្រីបានរៀនសុភាសិតថ្មីមួយថា "មានមិត្តភក្តិម្នាក់បន្ថែមទៀត ប្រៀបដូចបើកផ្លូវមួយបន្ថែមទៀត ហើយចេះភាសាមួយបន្ថែមទៀត ប្រៀបដូចបើកបង្អួចមួយបន្ថែមទៀត"។ នាងបន្ថែមថា ចូរយើងប្រើប្រាស់ភាសាជាស្ពាន ហើយពួតដៃគ្នាដើម្បីបង្កើតអនាគតដ៏ភ្លឺស្វាងសម្រាប់តំបន់ឡានឆាង-មេគង្គ។

កញ្ញា Udomsab Miss Jaruwan មកពីប្រទេសថៃ៖ ការសាកសួរសុខទុក្ខគ្នានៅខេត្តយូណាន

កញ្ញា Udomsab Miss Jaruwan ជាអ្នកសរសេរប្លុកជនជាតិថៃម្នាក់រស់នៅក្នុងខេត្តយូណាន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នាងបានចូលរួមថតរឿងភាគឯកសារខ្នាតតូចជាភាសាថៃ "តោះ ទៅសាកសួរសុខទុក្ខមិត្តខេត្តយូណាន" ដោយបានចូលរួមក្នុងសកម្មភាពផ្លាស់ប្តូរវប្បធម៌ផ្សេងៗ និងបានទៅទស្សនាផ្ទះរបស់អ្នកស្រុកយូណានគ្រប់គ្នា។

ដោយសារតែចូលរួមក្នុងកម្មវិធី "តោះ ទៅសាកសួរសុខទុក្ខមិត្តខេត្តយូណាន" នាងបានចូលពិធីបុណ្យជាច្រើនក្នុងតំបន់ ហើយទទួលបានសមាជិកគ្រួសារដ៏កក់ក្តៅនៅខេត្តយូណានផងដែរ។ នៅខែតុលា ឆ្នាំមុន នាងបានធ្វើដំណើរទៅកាន់ស្រុកលូឈុន ក្នុងមណ្ឌលស្វយ័តជនជាតិហានី និងយី ហុងហ៊ី ដើម្បីចូលរួមពិធីជប់លៀងតុវែង នៅទីនោះ មានតុជាងមួយពាន់តុដែលត្រូវបានរៀបចំតាមដងផ្លូវ មើលទៅពិតជាអស្ចារ្យណាស់។

នាងបាននិយាយថា តាមរយៈការសាកសួរសុខទុក្ខគ្នានៅខេត្តយូណានទាំងនេះ នាងមិនត្រឹមតែទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីខេត្តយូណានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្លាស់ប្តូរជីវិតក្នុងសុបិនក្លាយទៅជាអាជីពដែលនាងស្រឡាញ់យ៉ាងជ្រាលជ្រៅបន្តិចម្តងៗ។

លោក Anongdeth Phetkaysone មកពីប្រទេសឡាវ៖ "ច្រករបៀងមាស" បង្កើតឱកាសថ្មីៗ

លោក Anongdeth Phetkaysone អគ្គនាយករងនៃក្រុមហ៊ុនរថភ្លើងឡាវ-ចិន បាននិយាយថា នៅឆ្នាំ ២០២១ ផ្លូវរថភ្លើងឡាវ-ចិនបានដាក់ឱ្យដំណើរការជាផ្លូវការ ដែលបង្កើតឱកាសថ្មីៗសម្រាប់ប្រទេសឡាវ។ ដូច្នេះហើយប្រទេសឡាវបានប្រែក្លាយពី "ប្រទេសមិនជាប់សមុទ្រលើដីគោក" ទៅជា "ប្រទេសតភ្ជាប់លើដីគោក" ហើយឆ្ពោះទៅក្នុងយុគសម័យថ្មីនៃការតភ្ជាប់។

ជាង ៤ ឆ្នាំក្រោយមក ផ្លូវរថភ្លើងនេះបានក្លាយជាក្បាលម៉ាស៊ីនដ៏សំខាន់មួយដែលជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅគ្រប់វិស័យនៅក្នុងប្រទេសឡាវ។ ថ្លៃដឹកជញ្ជូនរវាងទីក្រុងវៀងចន្ទន៍ និងទីក្រុងគុនមីងបានធ្លាក់ចុះយ៉ាងខ្លាំងប្រសិទ្ធភាពភស្តុភារកម្មមានភាពប្រសើរឡើង គួរឱ្យកត់សម្គាល់ ដែលផ្តល់ឱ្យវាភាពងាយស្រួលយ៉ាងច្រើនសម្រាប់កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូររវាងសហគ្រាសនៅក្នុងប្រទេសទាំងពីរ។

លោកជឿជាក់យ៉ាងមុតមាំថា "ច្រករបៀងមាស" នេះនឹងក្លាយទៅជាវេទិកាដ៏រឹងមាំមួយសម្រាប់ភាពរុងរឿងរួមគ្នាក្នុងតំបន់ លើកកម្ពស់លំហូរទំនិញដោយរលូន និងការផ្ទារភ្ជាប់បេះដូងរវាងប្រជាជន និងប្រជាជន។

លោកស្រី Nguyen Thi Nhu Van÷ សមាហរណកម្មក្នុងតំបន់ជាគន្លឹះក្នុងការសម្រេចបាននូវការផ្លាស់ប្តូរបៃតង

លោកស្រី Nguyen Thi Nhu Van សាស្ត្រាចារ្យនៅមហាវិទ្យាល័យគ្រប់គ្រងឧស្សាហកម្ម និងថាមពលនៃសាកលវិទ្យាល័យថាមពលអគ្គិសនីវៀតណាម បានកត់សម្គាល់ថា ប្រទេសវៀតណាមកំពុងពន្លឿនការផ្លាស់ប្តូរថាមពលបៃតងរបស់ខ្លួន។ រដ្ឋាភិបាលវៀតណាមបានអនុម័តផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ថាមពលថ្មីមួយដែលមានគោលបំណងជំរុញសមត្ថភាពផលិតថាមពលកកើតឡើងវិញ និងកាត់បន្ថយការបំភាយកាបូន។

លោកស្រីបានបន្ថែមថា សមាហរណកម្មក្នុងតំបន់ជាគន្លឹះក្នុងការសម្រេចបាននូវការផ្លាស់ប្តូរបៃតង ប្រទេសវៀតណាមកំពុងពង្រឹងការភ្ជាប់បណ្តាញអគ្គិសនីជាមួយប្រទេសឡាវ កម្ពុជា និងចិន ដើម្បីពង្រីកបណ្តាញផ្គត់ផ្គង់ថាមពល។ កិច្ចសហប្រតិបត្តិការរវាងប្រទេសវៀតណាម និងចិនលើវិស័យបញ្ជូនថាមពល UHV និងបណ្តាញឆ្លាតវៃ នឹងជួយលើកកម្ពស់តួនាទីរបស់ប្រទេសវៀតណាមក្នុងតំបន់៕

瀾湄国传 Mekong News Network
http://www.yunnangateway.com/

អ្នកនិពន្ធភាសាចិន៖ RAN XIULAN អ្នកនិពន្ធភាសាខ្មែរ៖ LI ZHA SHEN YAN រចនារូបភាព៖ SUN YONGGANG